**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

# សេចក្តីថ្លែងការណ៍

## របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
## ស្តីពីរបាយការណ៍របស់តំណាងពិសេស
## នៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ទទួលអារម្មណ៍វាយប្រហារដោយផ្ទាល់ដោយសេចក្តីថ្លែងការណ៍ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប នៅថ្ងៃទី ២៦ ខែ កញ្ញា ដែលធ្វើឡើងដោយ លោក Yash Ghai តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

លោក Ghai បាននិយាយអំពី "*ដំណើរការប្រជាធិបតេយ្យបញ្ឆោតភ្នែក* " និងមានគណបក្សនយោបាយមួយបាន " *កាន់កាប់ទាំងស្រុងលើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត* "

ដោយបានប្រើសំដីអះអាងខាងលើទុកដូចជាហេតុការណ៍ដែលមិនអាចប្រកែកបាននោះ លោក Ghai បានវាយតំលៃ គ.ជ.ប ដោយពុំទុកឱកាសឱ្យ គ.ជ.ប ធ្វើការបកស្រាយទៅលើបញ្ហាខាងលើឡើយ ។

ទស្សនះរបស់លោក ទាក់ទងនឹងឯករាជភាព និងអព្យាក្រឹតភាពរបស់ គ.ជ.ប គឺជាការមិនត្រឹមត្រូវ ។ នៅកម្ពុជា សមាជិក របស់ គ.ជ.ប ត្រូវបានច្បាប់កំណត់មិនឱ្យធ្វើជាតំណាងគណបក្សណាមួយឡើយ ។

សេចក្តីថ្លែងការណ៍របស់លោក Ghai បានបង្ហាញពីការសន្មតទុកជាមុនដែលថា សមាជិក គ.ជ.ប បើទោះបីជាត្រូវកំណត់ដោយច្បាប់ឱ្យប្រកាន់ជំហរអព្យាក្រឹតឥតលំអៀងក៏ដោយ ក៏កំពុងតែក្បត់នឹងពាក្យសម្បថយ៉ាងឧឡារិករបស់ខ្លួន និងកំពុងតែដើរតួត្រឹមតែជាភ្នាក់ងាររបស់គណបក្សនយោបាយមួយតែប៉ុណ្ណោះ ។ តាមទស្សនះខាងលើ ការសន្និដ្ឋានរបស់លោក Ghai ចំពោះ គ.ជ.ប មិនស្របនឹងអ្វីដែលត្រូវបានរាយការណ៍ដោយអ្នកកាន់តំណែងមុនលោកឡើយ ។

បើតាមអ្វីដែល គ.ជ.ប បានដឹងផ្ទុយពីអ្នកកាន់តំណែងមុនលោក លោក Ghai និងអ្នករួមការងារជាមួយសុទ្ធតែមិនធ្លាប់មកទស្សនៈកិច្ចនៅ គ.ជ.ប ក្នុងអំឡុងពេល ៣ ឆ្នាំចុងក្រោយ ខុសពីអ្វីដែលអ្នកកាន់តំណែងមុនលោកបានធ្វើកន្លងមក ។ ជាថ្មីម្តងទៀត តាមអ្វីដែល គ.ជ.ប បានដឹង ខុសពីអ្នកកាន់តំណែងមុនលោក លោក Ghai មិនដែលមានឱកាសបានសង្កេតមើលការងារបោះឆ្នោតនៅកម្ពុជាដោយខ្លួនលោកផ្ទាល់ឡើយ ។

គ.ជ.ប ស្វាគមន៍រាល់អនុសាសន៍ និងមតិទិតៀនរបស់ភាគីដែលពាក់ព័ន្ធនឹងការងារបោះឆ្នោត ក៏ប៉ុន្តែ គ.ជ.ប មានសេចក្តីសោកស្តាយដោយក្នុងសេចក្តីថ្លែងការណ៍របស់លោក ពុំបានថ្លែងអំពីគំរូនៃ "*ការចូលរួមស្ថាបនា* " ដែលលោកបានចាត់ទុកវាជា "*ការទទួលខុសត្រូវជាចំបងរបស់លោក*" នៅក្នុងកថាខ័ណ្ឌទី ១ នៃរបាយការណ៍នោះ ។

នៅក្នុងរបាយការណ៍នោះដែរ លោក Ghai មានបំណងស្វះស្វែងរក " ការបន្តកិច្ចពិភាក្សាលើបញ្ហាទាំងនេះ " ប៉ុន្តែ គ.ជ.ប សូមស្នើជាយោបល់ថាកិច្ចពិភាក្សាដែលលើកឡើងនេះ គប្បីចាប់ផ្តើមធ្វើជាមួយនឹង គ.ជ.ប ជាមុនសិនមុននឹងធ្វើការសន្និដ្ឋាន ។

គ.ជ.ប មានបំណងអញ្ជើញតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ដើម្បីជួបពិភាក្សាជាមួយ គ.ជ.ប ជាពិសេសនៅមុនពេលដែលលោកត្រូវធ្វើសេចក្តីថ្លែងការណ៍ជូនអង្គការសហប្រជាជាតិ អំពីការងារបោះឆ្នោតនៅកម្ពុជា ។

ភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៦